ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៣១ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការអនុវត្តវិធានការការពារ និងថែទាំសុខភាពភ្នែក
# នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន

កម្មវិធីជាតិសុខភាពភ្នែក នៃក្រសួងសុខាភិបាលបានសិក្សាឃើញថា ជំងឺភ្នែកដែលកើតមានញឹកញាប់ចំពោះកុមារមានដូចជា ជំងឺភ្នែកក្រហម ជំងឺរលាកត្របកភ្នែក ភ្នែកអាឡែកហ្ស៊ី ជំងឺភ្នែកស្ងួត និងរបួស ឬប៉ះទង្គិចគ្រាប់ភ្នែកជាដើម។ តាមរបាយការណ៍ឆ្នាំ២០១១ កម្មវិធីជាតិសុខភាពភ្នែក នៃក្រសួងសុខាភិបាល បានបញ្ជាក់ថាក្នុងចំណោមកុមារ ១០ ០០០នាក់ មានកុមារ ១២នាក់ពិការភ្នែក ក្នុងនោះ ៥៥%បណ្តាលមកពីបញ្ហាសម្លាកកញ្ចក់ភ្នែក ១០%បណ្តាលមកពីបញ្ហាភ្នែកឡើងបាយពីកំណើត ៣%បណ្តាលមកពីរបួសភ្នែក និង ៣២%បណ្តាលមកពីជំងឺភ្នែកតំណពូជ។ លើសពីនេះ កុមារស្ថិតក្នុងវ័យសិក្សាមានហានិភ័យដោយសារគំហើញចុះខ្សោយរហូតដល់ ១៣,៧% ដែលបណ្តាលមកពីកំហុសកំណុំរូបភាព ហើយអត្រានេះនឹងអាចកើនច្រើនឡើងនាពេលបច្ចុប្បន្ន។

ក្នុងគោលបំណងជំរុញការអនុវត្តវិធានការការពារសុខភាពភ្នែក ដោយបន្ថែមលើខ្លឹមសារនៃសេចក្តីណែនាំនៅក្នុងមេរៀន ស្តីពីការអប់រំសុខភាពភ្នែក និងចូលរួមចំណែកលុបបំបាត់ភាពពិការភ្នែក និងបង្ការជំងឺភ្នែក ដូចបានរៀបរាប់ខាងលើ ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនទាំងអស់ ត្រូវធ្វើការណែនាំបន្តដល់បុគ្គលិកអប់រំ និងអ្នកសិក្សាឱ្យអនុវត្តវិធានការដូចខាងក្រោម ៖

- ពេលអាន ឬសរសេរ ត្រូវស្ថិតនៅចម្ងាយយ៉ាងតិច ៣០សង់ទីម៉ែត្រ ពីសៀវភៅ ឬក្រដាស ហើយត្រូវរកទីតាំងដែលមានពន្លឺគ្រប់គ្រាន់ តែមិនត្រូវប្រើពន្លឺចាំងខ្លាំងពេក ឬខ្សោយពេកនោះទេ
- ការអាន ការមើលទូរទស្សន៍ ការប្រើកុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិកដទៃទៀតដូចជាទូរស័ព្ទទំនើបជាដើម ក្នុង១ម៉ោង ត្រូវសម្រាកពី ១០ទៅ ១៥នាទី និងមិនត្រូវដេកអាន ឬប្រើប្រាស់ឧបករណ៍ទាំងនេះឡើយ



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៣ /២១៧ ២៥៣ /៤២៦ ៩៤១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crmoeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

- ចំពោះអ្នកដែលមានអាយុចាប់ពី៤០ឆ្នាំឡើងទៅ ត្រូវទៅពិនិត្យភ្នែកឱ្យបានម្តងក្នុង១ឆ្នាំ
- ត្រូវទទួលទានទឹកឱ្យបានច្រើន និងទទួលទានអាហារឱ្យបានគ្រប់គ្រាន់ ពិសេសត្រូវបរិភោគអាហារសម្បូរជីវជាតិអា ដូចជា បន្លែពណ៌បៃតង ផ្លែឈើពណ៌លឿងទុំ ស៊ុត ថ្លើមសត្វ។ល។
- ពេលភ្នែកមានជំងឺ ហាមព្យាបាលដោយខ្លួនឯង ឬព្យាបាលតាមគ្នា ឬព្យាបាលតាមអបិយជំនឿផ្សេងៗ និងហាមប្រើថ្នាំបុរាណដាក់ភ្នែក ជំនួសវិញត្រូវទៅទទួលសេវាព្យាបាលពីគ្រូពេទ្យឯកទេសភ្នែក
- ករណីកុមារមានជំងឺភ្នែកក្រហម ត្រូវនាំទៅមន្ទីរពេទ្យ ដើម្បីព្យាបាល និងឱ្យកុមារនោះឈប់សម្រាករហូតជាសះស្បើយ ដើម្បីបង្ការការឆ្លងជំងឺទៅអ្នកដទៃ
- ត្រូវជៀសវាងការពាក់កែវលើកញ្ចក់ភ្នែកពេលមានជំងឺភ្នែកក្រហម
- ករណីមានគ្រោះថ្នាក់ដោយវត្ថុជុងជាប់ភ្នែកកុំព្យាយាមចាប់យកវត្ថុដែលមុតនោះចេញពីភ្នែក ត្រូវទៅទទួលសេវាព្យាបាលពីគ្រូពេទ្យឯកទេសភ្នែកជាបន្ទាន់។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា គ្រប់រាជធានី ខេត្ត ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ ក្រុង ស្រុក និងគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដើម្បីអនុវត្តសេចក្តីណែនាំនេះ ឱ្យបានលទ្ធផលល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញថ្ងៃទី៣០ខែមិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**ចម្លងជូន**
- គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ
  *"ដើម្បីជូនជ្រាប និងសហការ"*
- សាលារាជធានីខេត្ត *"ដើម្បីជូនជ្រាប"*
- មន្ទីរ អយក រាជធានីខេត្ត *"ដើម្បីមុខការ"*
- អង្គភាពពាក់ព័ន្ធក្រោមឱវាទ *"ដើម្បីមុខការ"*
- គ្រប់គ្រឹះស្ថានសិក្សា *"ដើម្បីអនុវត្ត"*
- កាលប្បវត្តិ
- ឯកសារ នសស